# វិធីបង់ថ្លៃចំណាយសម្រាប់ការយកកូនចេញ
## នៅក្នុងខោនធី Los Angeles



## ជាសមាជិកកម្មវិធីធានារ៉ាប់រង MEDI-CAL ឬ?

ជាមួយនឹងកម្មវិធីធានារ៉ាប់រង Medi-Cal អ្នកអាចទទួលបានការថែទាំផ្នែកការយកកូនចេញដែលមានរក្សាការសម្ងាត់ **ដោយមិនគិតថ្លៃចំពោះអ្នក ហើយដោយមិនគិតអំពីអាយុរបស់អ្នកផងដែរ។** កម្មវិធីធានារ៉ាប់រង Medi-Cal ចេញថ្លៃចំណាយចំពោះការធ្វើដំណើរទៅទទួលយកការថែទាំផ្នែកការយកកូនចេញតាមរយៈ **សេវាកម្មផ្នែកអត្ថប្រយោជន៍ទាក់ទងទៅនឹងការធ្វើដំណើរ** របស់ពួកគេ។

## មានធានារ៉ាប់រងឯកជនឬ?

ច្បាប់នៃរដ្ឋ California តម្រូវចាំបាច់ឱ្យផែនការធានារ៉ាប់រងសុខភាពឯកជន**ភាគច្រើន** ចេញថ្លៃចំណាយចំពោះសេវាកម្មផ្នែកការយកកូនចេញ **ដោយមិនមានការបង់ប្រាក់ដែលនៅសេសសល់ក្រោយក្រុមហ៊ុនធានារ៉ាប់រងបានបង់ខ្លះរួច (co-payment) ឬការបង់ប្រាក់ឱ្យបានគ្រប់កម្រិតផែនការធានារ៉ាប់រង (deductible) ឬក៏ការចែករំលែកការចេញថ្លៃចំណាយក្នុងប្រភេទណាមួយឡើយ។**

## មិនមានធានារ៉ាប់រងសុខភាពឬ?

ប្រសិនបើអ្នករស់នៅក្នុងរដ្ឋ California ហើយមានសិទ្ធិដោយផ្អែកទៅលើប្រាក់ចំណូលនោះ អ្នកអាចទទួលបានការចេញថ្លៃចំណាយជូនជាបណ្ដោះអាសន្ន**ភ្លាមៗ**ដោយកម្មវិធីធានារ៉ាប់រង Medi-Cal សម្រាប់ការថែទាំផ្នែកការយកកូនចេញតាមរយៈ កម្មវិធីការមានសិទ្ធិទទួលបានជំនួយតាមការសន្មតសម្រាប់ស្ត្រីមានផ្ទៃពោះ (Presumptive Eligibility for Pregnant Woman Program/PE4PW)។ **ទទួលបានជំនួយនៅលើគេហទំព័រ៖** http://publichealth.lacounty.gov/mch/choi/CHOIContractorListEngSp.pdf។

**អ្នកមិនចាំបាច់ត្រូវផ្ដល់ប័ណ្ណសម្គាល់ខ្លួន ឬភ័ស្តុតាងនៃការមានសិទ្ធិរស់នៅឡើយ។** នៅពេលដែលបានចុះឈ្មោះនៅក្នុងកម្មវិធី PE4PW រួចហើយនោះ អ្នកអាចស្នើសុំការចេញថ្លៃចំណាយជូនដែលពេញលេញដោយកម្មវិធីធានារ៉ាប់រង Medi-Cal និងអាចពន្យារកម្មវិធីធានារ៉ាប់រង Medi-Cal សម្រាប់រយៈពេលមួយឆ្នាំទៀតបាន បន្ទាប់ពីពេលមានផ្ទៃពោះរបស់អ្នករួច។

## មិនមានសញ្ជាតិអាមេរិកឬ?

ជនអន្តោប្រវេសន៍គ្រប់អាយុដែលមានសិទ្ធិដោយផ្អែកទៅលើប្រាក់ចំណូល មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីទទួលបានការថែទាំសុខភាពពេញលេញតាមរយៈ កម្មវិធីធានារ៉ាប់រង Medi-Cal **ដោយមិនគិតអំពីស្ថានភាពនៃឯកសារស្នើសុំសញ្ជាតិឡើយ។** រដ្ឋ California មិនចែករំលែកព័ត៌មានផ្នែកអន្តោប្រវេសន៍ជាមួយនឹងអាជ្ញាធររដ្ឋាភិបាលទាំងឡាយនោះទេ ហើយ ការចុះឈ្មោះចូលកម្មវិធីធានារ៉ាប់រង Medi-Cal នឹងមិនប៉ះពាល់ដល់ឱកាសនៃការស្នើសុំសិទ្ធិរស់នៅដោយស្របច្បាប់ឡើយ។

## មកពីរដ្ឋផ្សេងឬ?

អ្នកមិនចាំបាច់ត្រូវជាពលរដ្ឋនៃរដ្ឋ California ដើម្បីទទួលបានការថែទាំផ្នែកការយកកូនចេញនៅទីនេះឡើយ ប៉ុន្តែរដ្ឋជាច្រើនមិនអនុញ្ញាតឱ្យមានការចេញថ្លៃចំណាយពីធានារ៉ាប់រងសម្រាប់ការយកកូនចេញនោះទេ។ សម្រាប់ព័ត៌មានបន្ថែមអំពីការទទួលបានជំនួយក្នុងការបង់ថ្លៃចំណាយសម្រាប់ការយកកូនចេញនៅក្នុងខោនធី Los Angeles **សូមមើលផ្នែក ធនធានផ្សេងៗនៅក្នុងរដ្ឋ California និងធនធានផ្សេងៗថ្នាក់ជាតិ នៅទំព័រទី 2។**

April 2024 (Cambodian)

ABORTION SAFE HAVEN PROJECT

COUNTY OF LOS ANGELES Public Health

# វិធីបង់ថ្លៃចំណាយសម្រាប់ការយកកូនចេញ
## នៅក្នុងខោនធី Los Angeles



### ត្រូវការជំនួយក្នុងការចេញថ្លៃចំណាយឬ?

- មូលនិធិផ្នែកការយកកូនចេញ (abortion funds) គឺជាអង្គការបែបឯកជនដែលអាចជួយចេញថ្លៃចំណាយនៃការយកកូនចេញបាន ក៏ដូចជា**ការចេញថ្លៃចំណាយពីហោប៉ៅទៅលើដំណើរការចាត់ចែងចំណុចផ្សេងៗ** រួមមានការធ្វើដំណើរ ការស្នាក់នៅ ថ្លៃម្ហូបអាហារ ការមើលថែទាំកុមារ សេវាកម្មបកប្រែឯកសារ អ្នកផ្តល់ជំនួយ (doulas/ឌូឡា) ផ្នែកការយកកូនចេញ និងការចំណាយផ្សេងទៀត ផងដែរ។
- **មូលនិធិផ្នែកការយកកូនចេញនានាមិនពិនិត្យរកស្ថានភាពអន្តោប្រវេសន៍ ឬភ័ស្តុតាងនៃការមានសញ្ជាតិឡើយ។**

### ធនធានផ្សេងៗនៅក្នុងតំបន់ និងនៅក្នុងរដ្ឋ California

- **អង្គការជំនួយសុខភាពរបស់ស្ត្រី និងអ្នកមានផ្ទៃពោះ (Maternal and Child Health Access/MCHA)** ផ្តល់ព័ត៌មានថាគួរតែធ្វើបែបណាទាក់ទងទៅនឹងការចេញថ្លៃចំណាយផ្នែកសុខភាព ហើយនិងផ្តល់ជំនួយដល់បុគ្គលទាំងឡាយ និងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់ពួកគេ ដើម្បីធានាថាការថែទាំគឺទាន់ពេលវេលា និងត្រឹមត្រូវ។
- ផ្តល់ជំនួយក្នុងការដោះស្រាយបញ្ហាទាក់ទងទៅនឹងការមានសិទ្ធិទទួលបានធានារ៉ាប់រង ជម្រើសនៃការចេញថ្លៃចំណាយជូន ហើយនិងការចុះឈ្មោះចូលកម្មវិធីធានារ៉ាប់រង Medi-Cal ឬ Covered California ឬ Medi-Cal Access Program ហើយនិងធានារ៉ាប់រងឯកជននានា ផងដែរ។
- អាចនឹងផ្តល់ជំនួយផ្នែកប្រាក់កាស និងជំនួយផ្សេងទៀតផ្នែកការយកកូនចេញចំពោះការចាយវាយ ដូចជាការមើលថែទាំកុមារ ការធ្វើដំណើរ និងការស្នាក់នៅ ជាដើម។
- លេខទូរស័ព្ទរបស់ MCHA៖ 213.749.4261។ ពួកគេនិយាយភាសាអេស្ប៉ាញ ផងដែរ។

- **ACCESS RJ** គឺជាអង្គការផ្នែកយុត្តិធម៌ទាក់ទងទៅនឹងការបន្តពូជដែលដាក់ដំណើរការបណ្តាញទូរស័ព្ទផ្តល់ព័ត៌មានផ្នែកសុខភាពមួយដែលមិនគិតថ្លៃ និងរក្សាការសម្ងាត់ ដើម្បីផ្តល់ធនធានផ្សេងៗដល់អ្នកដែលត្រូវការចំណុចថែទាំផ្នែកការយកកូនចេញ និងការថែទាំសុខភាពផ្នែកបន្តពូជផ្សេងទៀត ហើយនិងផ្តល់ធនធានផ្សេងៗដល់អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាព។ អង្គការនេះមានផ្តល់ការប្រឹក្សាពីអ្នកដែលមានអាយុប្រហាក់ប្រហែលគ្នា និងការបញ្ជូនឈ្មោះ ផងដែរ។
- មានផ្តល់ជូនទឹកប្រាក់ និងជំនួយសម្រាប់ការថែទាំសុខភាព ការធ្វើដំណើរ ការមើលថែទាំកុមារ ថ្លៃម្ហូបអាហារ និងការស្នាក់នៅ ជាដើម។
  - បណ្តាញទូរស័ព្ទផ្តល់ព័ត៌មានផ្នែកសុខភាពជាភាសាអង់គ្លេស៖ 800.376.4636។ បណ្តាញទូរស័ព្ទជាភាសាអេស្ប៉ាញ៖ 888.442.2237។
  - បណ្តាញសារជាអក្សរផ្តល់ព័ត៌មានផ្នែកសុខភាព៖ 510.925.0335។ គេហទំព័រ៖ accessrj.org។

### ធនធានផ្សេងៗថ្នាក់ជាតិ

- **បណ្តាញថ្នាក់ជាតិនៃមូលនិធិផ្នែកការយកកូនចេញ (National Network of Abortion Funds/NNAF)** គឺជាបណ្តាញនៃមូលនិធិឯករាជ្យចំនួន 100 នៅទូទាំងសហរដ្ឋអាមេរិក ដែលផ្តល់ទាំងជំនួយផ្នែកប្រាក់កាស និងជំនួយផ្នែកដំណើរការចាត់ចែងចំណុចផ្សេងៗ រួមមានការធ្វើដំណើរទៅរដ្ឋផ្សេងផងដែរ។
  - ស្វែងរកធនធានផ្សេងៗសម្រាប់រដ្ឋរបស់អ្នក នៅលើគេហទំព័រនេះ៖ abortionfunds.org/find-a-fund។
- **បណ្តាញទូរស័ព្ទបន្ទាន់ថ្នាក់ជាតិទាក់ទងទៅនឹងការយកកូនចេញ (National Abortion Hotline)** អាចផ្តល់ព័ត៌មានអំពីអ្នកផ្តល់សេវាកម្មផ្នែកការយកកូនចេញទាំងឡាយ និងជំនួយផ្នែកប្រាក់កាសដែលមានកំណត់ នៅក្នុងសហរដ្ឋអាមេរិក និងប្រទេសកាណាដា។
  - បណ្តាញទូរស័ព្ទបន្ទាន់ដែលមានជាច្រើនភាសា៖ 800.772.9100។ បណ្តាញសន្ទនាបន្ទាន់ នៅលើគេហទំព័រ៖ prochoice.org/patients/naf-hotline។

### តើអ្នកមានការព្រួយបារម្ភអំពីការលាក់កំបាំងដែរឬទេ?

- **មានការហាមឃាត់មិនឱ្យ**អ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពទាំងឡាយនៅក្នុងរដ្ឋ California **ផ្សព្វផ្សាយកំណត់ត្រាផ្នែកពេទ្យ**របស់អ្នកដែលកំពុងស្វែងរកការថែទាំផ្នែកការយកកូនចេញ ទៅកាន់មន្ត្រីប៉ូលីសឡើយ (យោងទៅតាម ការិយាល័យរបស់អភិបាលរដ្ឋ (Office of Governor)។
- សម្រាប់ពលរដ្ឋនៃរដ្ឋ California ច្បាប់នៃការរក្សាការសម្ងាត់នៃព័ត៌មានផ្នែកសុខភាព (Confidential Health Information Act/CHIA) អនុញ្ញាតឱ្យអ្នកការពារព័ត៌មានផ្នែកសុខភាពរបស់អ្នក បើទោះបីជាអ្នកមានឈ្មោះនៅក្នុងផែនការថែទាំសុខភាពរបស់មនុស្សម្នាក់ទៀតក៏ដោយ។
- តាមរយៈ CHIA អ្នកអាចដាក់**សំណើរអំពីការទំនាក់ទំនងដោយសម្ងាត់ (Confidential Communications Request)** ទៅកាន់អ្នកផ្តល់សេវាកម្មធានារ៉ាប់រងរបស់អ្នកបាន តាមរយៈគេហទំព័រ myhealthmyinfo.org។ (នេះគឺជាសំណើរបញ្ឈប់ការចែករំលែកព័ត៌មានផ្នែកសុខភាពរបស់អ្នកជាមួយនឹងអ្នកផ្សេងទៀតដែលមានឈ្មោះនៅក្នុងផែនការថែទាំសុខភាព សូម្បីតែប្តី ឬប្រពន្ធក៏ដោយ។)
- ចូរពិភាក្សាជាមួយនឹងអ្នកផ្តល់សេវាកម្មផ្នែកថែទាំសុខភាពរបស់អ្នកអំពីវិធីដែលពួកគេអាចការពារការលាក់កំបាំងរបស់អ្នកឱ្យបានល្អបំផុត។

April 2024 (Cambodian)

ABORTION SAFE HAVEN PROJECT

COUNTY OF LOS ANGELES Public Health